

# ក្របខណ្ឌកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ ២០២៤-២០២៨

## សេចក្តីសង្ខេប

UNITED NATIONS
CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្របខណ្ឌកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ ២០២៤-២០២៨

សេចក្តីសង្ខេប

ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ ៥៣ ផ្លូវប៉ាស្ទ័រ សង្កាត់បឹងកេងកង១ ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ៖ 877
+855 (0) 23 216 167, Ext. 1335
https://cambodia.un.org

ក្របខណ្ឌកិច្ចសហប្រតិបត្តិការ
អភិវឌ្ឍន៍ប្រកបដោយចីរភាព
របស់អង្គការសហប្រជាជាតិ
ឆ្នាំ ២០២៤-២០២៨



# គោលបំណង

ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអង្គការសហប្រជាជាតិ “ក្រប ខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍” សម្រាប់ប្រទេសកម្ពុជា ២០២៤-២០២៨ គឺជាឯកសារយុទ្ធសាស្ត្រមួយដែលបង្ហាញការគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការរួមចំណែកដល់អាទិភាពនៃការអភិវឌ្ឍជាតិប្រកបដោយប្រសិទ្ធភាព ដូចដែលមានបង្ហាញនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងដើម្បីសម្រេចឲ្យបាននូវវឌ្ឍនភាពចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ការចាកចេញពីស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួច និងចក្ខុវិស័យឆ្នាំ២០៥០ របស់កម្ពុជា។

អាទិភាព (priority) លទ្ធផល (outcome) និងធាតុចេញ (output) ដែលមាននៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ មានភាពស៊ីសង្វាក់គ្នាយ៉ាងជិតស្និទ្ធជាមួយនឹង អាទិភាព និងគោលដៅដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះបង្ហាញពី អាទិភាព និង កិច្ចអន្តរាគមន៍សំខាន់ៗដែលបានកំណត់រួមគ្នាដោយក្រុមការងារអង្គការសហប្រជាជាតិដៃគូរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់បញ្ហាអភិវឌ្ឍអាទិភាពជាតិ។

# បរិបទប្រទេស

កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចថេរក្នុងរង្វង់ ៧,៧% នៃ ផ.ស.ស ចន្លោះពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១៩ នៅមុនពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩។ វឌ្ឍនភាពនេះបាននាំឱ្យមានការថយចុះនៃភាពក្រក្រីក្នុងកម្រិតមួយខ្ពស់ពី ៤៧,៨% ក្នុងឆ្នាំ ២០០៧ មក ១៧,៨% ក្នុងឆ្នាំ ២០១៩។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) បានកើនឡើង ៥៦,៩% ចន្លោះពីឆ្នាំ ១៩៩០ ដល់ឆ្នាំ២០២១ ធ្វើឲ្យកម្ពុជាឈានដល់ក្រុមប្រទេសដែលមានការអភិវឌ្ឍន៍មនុស្សកម្រិតមធ្យម និងនាំឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៤៦ទូទាំងសកលលោកក្នុងឆ្នាំ២០២១។ កម្ពុជារំពឹងថានឹងចាកចេញពីស្ថានភាពជាប្រទេសដែលមានការអភិវឌ្ឍតិចតួចក្នុងឆ្នាំ ២០២៧ និងប្រាថ្នាក្លាយជាប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០។

កម្ពុជាស្ថិតនៅដំណាក់កាលសំខាន់មួយនៃការកសាងផែនការអភិវឌ្ឍជាតិ។ ទន្ទឹមនេះកម្ពុជានឹងបន្តជួបប្រទះបញ្ហាប្រឈមដែលធ្វើឱ្យរាំងស្ទះដល់ការសម្រេចបានវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ បញ្ហាប្រឈមទាំងនោះរួមមាន សេដ្ឋកិច្ចមួយភាគធំមានលក្ខណៈក្រៅប្រព័ន្ធ ភាពក្រីក្រពហុសមាសភាគនៅតែបន្តមាន ការពឹងអាស្រ័យលើវិស័យកសិកម្ម ប្រព័ន្ធអប់រំ និងភាពងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនោះ កម្ពុជានឹងជួបបញ្ហាប្រឈមថ្មីក្នុងវិថីឆ្ពោះទៅកាន់ប្រទេសដែលមានចំណូលខ្ពស់ និងតម្រូវការដើម្បីសម្របខ្លួនទៅនឹងបំរែបំរួលនិន្នាការពិភពលោក។



# សារតា

## មិនទុកនរណាម្នាក់ចោល

ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបានរៀបចំ ឡើង ដោយផ្អែកតាមគោលការណ៍អភិក្រមគ្រប់ជ្រុង ជ្រោយសម្រាប់សិទ្ធិមនុស្ស។ យុទ្ធសាស្ត្រសិទ្ធិមនុស្ស របស់ប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា ២០២១- ២០២៨ និងការឈ្វេងយល់លម្អិតអំពីស្ថានភាពយេនឌ័រ បានរួមចំណែកយ៉ាងសំខាន់ដល់ការរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ។ លទ្ធផលទាំង៤ផ្តោតសំខាន់លើបរិយាបន្ន និងការចូលរួម ដោយធានាថា មិនមាននរណាម្នាក់ត្រូវបានគេទុកចោល។

## ការវិភាគទៅលើបរិបទប្រទេស

ការវិភាគរួមគ្នា ទៅលើស្ថានភាពរបស់ប្រទេសកម្ពុជាផ្តល់នូវព័ត៌មានលម្អិតសម្រាប់ឈ្វេងយល់ពីមូលហេតុ ឫសគល់ នៃបញ្ហាប្រឈមក្នុងការអភិវឌ្ឍនៅកម្ពុជា។ ដំណើរការរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ២០២៤ -២០២៨ សម្រាប់កម្ពុជានេះ ត្រូវបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋានទិន្នន័យ ភស្តុតាង និង យោងទៅលើលទ្ធផលនៃការវិភាគរួមគ្នាលើស្ថានភាពរបស់ប្រទេសកម្ពុជា។

## ការវាយតម្លៃ UNDAF ២០១៩-២០២៣

លទ្ធផលនៃការវាយតម្លៃឯករាជ្យ លើក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDAF ២០១៩-២០២៣) បានផ្តល់នូវពត៌មាន និងបទ ពិសោធន៍អំពីអ្វីដែលបានដំណើការល្អ និងអ្វីដែលចាំបាច់ត្រូវកែតម្រូវដល់ដំណើការរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ។



# កាលបរិច្ឆេទ និងដំណើរការ




យុទ្ធសាស្ត្រ និងលទ្ធផលដែលបានដាក់ចេញក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបានធ្វើឡើងតាមរយៈដំណើរការពិគ្រោះយោបល់ដោយមានការចូលរួម ដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍ចំបងៗ។ អាទិភាព យុទ្ធសាស្ត្រ លទ្ធផល និងធាតុចេញ ត្រូវបានកំណត់តាមរយៈកិច្ចពិភាក្សា ការចូលរួមយ៉ាងជិតស្និទ្ធពីសំណាក់ភាគីពាក់ព័ន្ធនានារួមមាន រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ ដៃគូអភិវឌ្ឍ និងវិស័យឯកជន។

## ក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០២៤-២០២៨

1 អាទិភាពទី ១ — ការអភិវឌ្ឍមនុស្ស

3 អាទិភាពទី ៣ — បរិស្ថាន

2 អាទិភាពទី ២ — បរិវត្តកម្មសេដ្ឋកិច្ច

4 អាទិភាពទី ៤ — បរិវត្តកម្មសង្គម

# ភាពស៊ីសង្វាក់គ្នានៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងអាទិភាពនៃការអភិវឌ្ឍជាតិ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព




## លទ្ធផលរបស់ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ២០២៤-២០២៨

## ការគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/របស់កម្ពុជា

### ១. ការអភិវឌ្ឍមនុស្ស

ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅក្នុងប្រទេសកម្ពុជា ជាពិសេសប្រជាជនដែលងាយត្រូវបានគេទុកចោល កាន់តែមានសុខភាពមាំមួន និងទទួលបានភាគផលពីការអប់រំ និងសេវាគាំពារសង្គមដែលកាន់តែប្រសើរ និងឆ្លើយតបនឹងយេនឌ័រ។

### ២. បរិវត្តកម្មសេដ្ឋកិច្ច

ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅកម្ពុជា ជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោលនឹងទទួលបានភាគផលនិងរួមចំណែកដល់សេដ្ឋកិច្ចដែលកាន់តែមានផលិតភាព ពិពិធភាព សមភាពយេនឌ័រ បានរៀបចំបញ្ចូលក្នុងប្រព័ន្ធ មានការបំភាយកាបូនទាប និងអាចបន្សាំនឹងអាកាសធាតុ។

### ៣. បរិស្ថាន

ត្រឹមឆ្នាំ២០២៨ ប្រជាជននៅកម្ពុជាជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោល នឹងទទួលបានភាគផលពីបរិយា កាសធម្មជាតិ ដែលកាន់តែប្រសើរជាងមុន និងមានបរិយាបន្នយេនឌ័រ។

### ៤. បរិវត្តកម្មសង្គម

ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅកម្ពុជា ជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោលនឹងរស់នៅក្នុងសង្គមដែលកាន់តែមានសមភាពយេនឌ័រ បរិយាបន្ន មានការផ្តល់លំហសេរីភាពដល់ពលរដ្ឋ និងមានស្ថាប័នដែលបំពេញការងារកាន់តែមានប្រសិទ្ធភាព និងកាន់តែមានគណនេយ្យភាព។



# របៀបដែលក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ត្រូវបានរៀបចំ

## លទ្ធផល (Outcome)

នៅក្នុងអាទិភាពនីមួយៗ នៃអាទិភាពទាំង៤ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ បានកំណត់យកលទ្ធផល១ ដែលអង្គការសហប្រជាជាតិចង់សម្រេចបាន ត្រឹមឆ្នាំ២០២៨។ ការសម្រេចបានលទ្ធផលទាំងនោះ គឺអាស្រ័យលើកិច្ចខិតខំប្រឹងប្រែង និងការចូលរួមពីគ្រប់ភាគីទាំងអស់។

## ធាតុចេញ (Outputs)

ធាតុចេញចំនួន១៧ នៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបានកំណត់ដើម្បីរួមចំណែកឲ្យសម្រេចបាននូវលទ្ធផលទាំង៤នៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលប្រព័ន្ធអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាត្រូវមានគណនេយ្យភាព។ ធាតុចេញទាំងនោះឆ្លុះបញ្ចាំងនូវការងារគ្រប់ទីភ្នាក់ងារអង្គការសហប្រជាជាតិ មូលនិធិ និងកម្មវិធី ដែលអនុវត្តរួមគ្នា និងដាច់ដោយឡែកពីគ្នា។

## គោលការណ៍ស្នូលនៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ការរៀបចំក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ធ្វើឡើងផ្អែកតាមគោលការណ៍ដូចខាងក្រោម៖

- ការអភិវឌ្ឍធ្វើឡើងដោយប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិមនុស្ស ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបរិយាបន្ន ការមិនទុកនរណាម្នាក់ចោល និងការពង្រីកវិសាលភាពគ្របដណ្តប់មុនគេ ដល់អ្នកដែលនៅក្រោយគេ
- សមភាពយេនឌ័រ និងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី
- ចីរភាព និងភាពធន់
- គណនេយ្យភាព និងតម្លាភាព។

## គំនិតផ្តួចផ្តើមដែលមានផលជះខ្ពស់ (High Impact Initiatives (HIIs)/Transitions)

គំនិតផ្តួចផ្តើមដែលមានផលជះខ្ពស់ត្រូវបានកំណត់ឡើងជាអាទិភាពសម្រាប់បរិវត្តកម្ម ដែលកម្ពុជាអាចរួមចំណែកដល់គោលដៅជាតិ និងគោលដៅសាកល។ គំនិតផ្តួចផ្តើមដែលមានផលជះខ្ពស់ទាំងនោះរួមមាន បរិវត្តកម្មការអប់រំ ប្រព័ន្ធស្បៀង ជីវៈចម្រុះនិងធម្មជាតិ ការគាំពារសង្គមនិងការងារ ថាមពល ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល ទិន្នន័យ និងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើហឹង្សាទៅលើស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌលទ្ធផលនៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

## ក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិឆ្នាំ ២០២៤-២០២៨



**ទីភ្នាក់ងារដែលចូលរួមក្នុងលទ្ធផលទី ១៖**

***FAO, ILO, IOM, OHCHR, UNAIDS, UNDP, UNESCO, UNFPA, UNICEF, UNIDO, UNITAR, UNODC, UNOPS, WFP, and WHO.***

**ធាតុចេញ ១.១៖** ការគ្របដណ្តប់សុខភាពជាសកល ត្រូវបានលើកកម្ពស់តាមរយៈ ប្រព័ន្ធសុខាភិបាលដែលធន់ និងផ្តោតសំខាន់លើប្រជាជន។

**ធាតុចេញ ១.២៖** ការការពារកាន់តែប្រសើរ ចំពោះបញ្ហាកង្វះអាហារូបត្ថម្ភគ្រប់ទម្រង់។

**ធាតុចេញ ១.៣៖** ការអប់រំ ការអភិវឌ្ឍជំនាញ និងការរៀនសូត្រពេញមួយជីវិត កាន់តែមានគុណភាព និងកាន់តែផ្តល់ភាពងាយស្រួល។

**ធាតុចេញ ១.៤៖** ប្រព័ន្ធគាំពារសង្គមត្រូវ បានកែលម្អ និងពង្រីកវិសាលភាព ដែលធ្វើឱ្យប្រជាពលរដ្ឋកាន់តែមានភាពធន់ ក្នុងគ្រាដែលពួកគេប្រឈមនឹងហានិភ័យ និងវិបត្តិសង្គមសេដ្ឋកិច្ច នៅគ្រប់ដំណាក់កាលនៃវដ្តជីវិត។

**ធាតុចេញ ១.៥៖** បង្កើនសន្តិសុខមនុស្សជាតិតាមរយៈសកម្មភាពកំចាត់មីន ដែលពង្រីកការទទួលបាននូវ ដីធ្លីប្រកបដោយសុវត្ថិភាព កាលានុវត្តភាពជីវភាព និងការគាំទ្រជនរងគ្រោះដោយសារមីន។



## លទ្ធផលទី ១៖ ការអភិវឌ្ឍមនុស្ស

**ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅក្នុងប្រទេសកម្ពុជា ជាពិសេសប្រជាជនដែលងាយត្រូវបានគេទុកចោល កាន់តែមានសុខភាពមាំមួន និងទទួលបានភាគផលពីការអប់រំ និងសេវាគាំពារសង្គមដែលកាន់តែប្រសើរ និងឆ្លើយតបនឹងយេនឌ័រ។**

**ធាតុចេញ ២.១៖** ប្រព័ន្ធស្បៀងកាន់តែមានប្រសិទ្ធភាព បន្សាំនឹងអាកាសធាតុ បរិយាបន្ន ត្រូវបានរៀបចំបញ្ចូលក្នុងប្រព័ន្ធ និងកាន់តែមានសុវត្ថិភាព។

**ធាតុចេញ ២.២៖** ធុរកិច្ចនានាត្រូវបានរៀបចំបញ្ចូលក្នុងប្រព័ន្ធ ប្រកបដោយបរិយាបន្ន មានការកាត់បន្ថយការបំភាយកាបូន និងការបំពុលបរិយាកាស។

## លទ្ធផលទី ២៖ បរិវត្តកម្មសេដ្ឋកិច្ច

**ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅកម្ពុជា ជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោល នឹងទទួលបានភាគផល និងរួមចំណែកដល់សេដ្ឋកិច្ចដែលកាន់តែមានផលិតភាព ពិពិធភាព សមភាពយេនឌ័រ បានរៀបចំបញ្ចូលក្នុងប្រព័ន្ធ មានការបំភាយកាបូនទាប និងអាចបន្សាំនឹងអាកាសធាតុ។**



**ធាតុចេញ ២.៣៖** លក្ខខណ្ឌការងារសមរម្យត្រូវបានជំរុញលើកកម្ពស់សម្រាប់ប្រជាជនឲ្យបានកាន់តែច្រើននាក់។

**ធាតុចេញ ២.៤៖** ធនធានហិរញ្ញប្បទានដើម្បីទ្រទ្រង់ដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានពីប្រភពកាន់តែចម្រុះ និងមាននិរន្តរភាព។



**ទីភ្នាក់ងារដែលចូលរួមក្នុងលទ្ធផលទី ២៖**

***FAO, ILO, IOM, IFAD, ITC,OHCHR, UNCDF, UNCTAD, UNDP, UNESCAP, UNEP, UNESCO, UNFPA, UNICEF, UNIDO, UN WOMEN, WFP, and WHO.***

**ទីភ្នាក់ងារដែលចូលរួមក្នុងលទ្ធផលទី ៣៖**
*FAO, IFAD, IOM, OHCHR, UNCDF, UNDP, UNDRR, UNEP, UNESCO, UNFPA, UN-HABITAT, UNIDO, UNICEF, UNOPS, UN WOMEN, WFP, and WHO.*





## លទ្ធផលទី ៣៖ បរិស្ថាន

ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅកម្ពុជា ជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោល នឹងទទួលបានភាគផលពីបរិយាកាសធម្មជាតិ ដែលកាន់តែប្រសើរជាងមុន និងមានបរិយាបន្នយេនឌ័រ។

**ធាតុចេញ ៣.១៖** សកម្មភាព គ្រប់គ្រង អភិរក្ស ការពារ និង ស្តារធនធានធម្មជាតិឡើងវិញ ត្រូវបានជំរុញបន្ថែម។

**ធាតុចេញ ៣.២៖** ការបំពុលខ្យល់ ទឹក និងដី ត្រូវបាន កាត់បន្ថយ និងមានការត្រួតពិនិត្យ លើសារធាតុគ្រោះថ្នាក់នានា។

**ធាតុចេញ ៣.៣៖** អភិបាលកិច្ច និងគោលនយោបាយឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ត្រូវបានពង្រឹង និងការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តវិធានការអាកាសធាតុត្រូវបានលើកជម្រុញ។

**ធាតុចេញ ៣.៤៖** សមត្ថភាពបន្សាំរបស់ប្រព័ន្ធ និងសហគមន៍ ចំពោះការប្រែប្រួលអាកាសធាតុ និង គ្រោះមហន្តរាយត្រូវបានពង្រឹងបន្ថែម។

## លទ្ធផលទី ៤៖ បរិវត្តកម្មសង្គម

ត្រឹមឆ្នាំ ២០២៨ ប្រជាជននៅកម្ពុជា ជាពិសេសប្រជាជនដែលងាយនឹងត្រូវបានគេទុកចោល នឹងរស់នៅក្នុងសង្គមដែលកាន់តែមានសមភាពយេនឌ័រ បរិយាបន្ន មានការផ្តល់លំហសេរីភាពដល់ពលរដ្ឋ និងមានស្ថាប័នដែលបំពេញការងារកាន់តែមាន ប្រសិទ្ធភាព និងកាន់តែមាន



**ធាតុចេញ ៤.១៖** ស្ថាប័ននានាកាន់តែមានគណនេយ្យភាព និងកាន់តែមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ដើម្បីផ្តល់នូវភាពយុត្តិធម៌ និងការការពារដល់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ និងពលករទេសន្តរប្រវេសន៍ ជាដើម។

**ធាតុចេញ ៤.២៖** ការចូលរួមរបស់ពលរដ្ឋ រួមទាំង ស្ត្រី និងយុវជន ក្នុងកិច្ចអភិវឌ្ឍន៍ និងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតទាំងអស់ ត្រូវបានបង្កើន។

**ធាតុចេញ ៤.៣៖** ប្រព័ន្ធសេវាកម្ម និងដំណោះស្រាយ នៅតាមសហគមន៍កាន់តែអាចឆ្លើយតប និងអាចទប់ស្កាត់ការរើសអើង អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ការរំលោភបំពាន ការកេងប្រវ័ញ្ចន៍ និងការអនុវត្តដែលអាចបង្កគ្រោះថ្នាក់ផ្សេងទៀត។

**ធាតុចេញ ៤.៤៖** បរិវត្តកម្មឌីជីថល ត្រូវបានជំរុញ ដើម្បីពន្លឿនការផ្លាស់ប្តូរសង្គមជាវិជ្ជមាន។

**ទីភ្នាក់ងារដែលចូលរួមក្នុងលទ្ធផលទី ៤៖**
*ILO, IOM, ITU, OHCHR, UNAIDS, UNDP, UNESCAP, UNESCO, UNFPA, UN-HABITAT, UNHCR, UNICEF, UNODC, UNV, UN WOMEN, WFP, and WHO.*

# សមាជិកប្រព័ន្ធអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា

UNITED NATIONS
CAMBODIA

---

Food and Agriculture Organization of the United Nations

IFAD INTERNATIONAL FUND FOR AGRICULTURAL DEVELPMENT

ILO

IOM UN MIGRATION

International Trade Centre

ITU

UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER Cambodia

UNAIDS

UNCDF Microfinance • Capital Development

UNITED NATIONS UNCTAD

UNDP

UNDRR UN Office for Disaster Risk Reduction

UN environment programme

UNITED NATIONS ESCAP Economic and Social Commission for Asia and the Pacific

unesco

UNFPA

UN-HABITAT FOR A BETTER URBAN FUTURE

UNHCR The UN Refugee Agency

unicef

UNIDO

UNODC United Nations Office on Drugs and Crime

UNOPS

UN VOLUNTEERS

UN WOMEN

WFP World Food Programme

World Health Organization